**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ០២/ខេ៣.ព្រ.គ អអរ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ដំណើរទស្សនកិច្ចលើកដំបូងជាប្រវត្តិសាស្ត្ររបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋប្រជាមានិតចិន ដោយសម្រេចបានសមិទ្ធផលជាក់ស្តែងថ្មីៗបន្ថែមទៀត ជូនជាតិមាតុភូមិ និងប្រជាជន

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូជាន់ខ្ពស់ បានអញ្ជើញមាតុភូមិនិវត្តន៍មកដល់រាជធានីភ្នំពេញវិញហើយ នាល្ងាចថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣នេះ បន្ទាប់ពីបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣ តបតាមការអញ្ជើញរបស់ **ឯកឧត្តម លី ឈាង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតចិន។ ទស្សនកិច្ចផ្លូវការរយៈពេល៤ថ្ងៃនេះ សម្រេចបានលទ្ធផលយ៉ាងធំធេងទាំងផ្នែកទំនាក់ទំនងការទូត និងកិច្ចសហប្រតិបត្តិការទ្វេភាគី ទាំងផលប្រយោជន៍សេដ្ឋកិច្ច និងការវិនិយោគ ក៏ដូចជាការជំរុញវិស័យទេសចរណ៍។

*ក្នុងក្របខ័ណ្ឌនៃទស្សនកិច្ចផ្លូវការ* **សម្តេចធិបតី** បានជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ **ឯកឧត្តម ចាវ ឡឺជី** ប្រធានសភាតំណាងប្រជាជនទូទាំងប្រទេស **ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតី និង **ឯកឧត្តម លី ឈាង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតចិន។ ក្នុងជំនួបដាច់ដោយឡែក ប្រកបដោយមនោសញ្ចេតនាមិត្តភាពដ៏ជ្រាលជ្រៅនោះ ថ្នាក់ដឹកនាំកំពូលៗចិន បានបង្ហាញការគាំទ្រ និងអបអរសាទរជាថ្មីទៀតជាមួយប្រជាជនកម្ពុជា ក្នុងឱកាសដែល **សម្តេចធិបតី** ត្រូវបានជ្រើសតាំងជានាយករដ្ឋមន្ត្រីសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា និងបានផ្តាំផ្ញើការសួរសុខទុក្ខដោយក្តីនឹករលឹកដ៏ស្មោះ ជូន **សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ** ដែលជាមគ្គុទ្ទេសក៍ឆ្នើមក្នុងប្រវត្តិសាស្ត្រ និងដែលបានពូនជ្រុំទំនាក់ទំនងការទូតកម្ពុជា-ចិន បន្តពីស្នាព្រះហស្ត និងស្នាដៃដ៏ឧត្តុង្គឧត្តមខ្ពង់ខ្ពស់របស់ **ព្រះមហាវីរក្សត្រ** និងថ្នាក់ដឹកនាំចិនគ្រប់ជំនាន់។ **ឯកឧត្តម** ប្រធានាធិបតីចិន មានប្រសាសន៍ថា **សម្តេចតេជោ** បានរួមចំណែក

ជាប្រវត្តិសាស្ត្រ ក្នុងបុព្វហេតុមិត្តភាពចិន-កម្ពុជា ជាពិសេសបានបើកសករាជថ្មី នៃការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មីប្រកបដោយគុណភាពខ្ពស់ កម្រិតខ្ពស់ និងស្តង់ដារខ្ពស់ និងគូសបញ្ជាក់ទៀតថា **ចំណងមិត្តភាពប្រទេសទាំងពីរ ប្រៀបបីដូចជាដើមឈើមួយដើមដ៏ធំដែលបានចាក់ឫសយ៉ាងជ្រៅ និងយ៉ាងរឹងមាំ ហើយប្រជាជាតិទាំងពីរបានទទួលផ្លែផ្កានិងផលប្រយោជន៍ជារៀងរហូតមិនអាចកាត់ថ្លៃបាន។**

ជាការឆ្លើយតប **សម្តេចធិបតី** បានថ្លែងអំណរគុណដល់រដ្ឋាភិបាលចិនដែលបានពិនិត្យ និងព្យាបាលព្រះរាជសុខភាពជាទៀងទាត់ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និង **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។ **សម្តេចធិបតី** បានជម្រាបថ្នាក់ដឹកនាំកំពូលៗចិនអំពីការផ្តាំផ្ញើនូវក្តីនឹករលឹកពី **សម្តេចតេជោ** ជូន **ឯកឧត្តមប្រធានាធិបតី** និងថ្នាក់ដឹកនាំកំពូលៗចិនផងដែរ។ ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា **សម្តេចធិបតី** ក៏បានថ្លែងអំណរគុណរដ្ឋាភិបាល និងប្រជាជនចិន សម្រាប់កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយប្រកបដោយមិត្តភាព ជាពិសេសការជំរុញ និងអនុវត្តនូវកិច្ចព្រមព្រៀងទាំងឡាយដែលរួមចំណែកធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាមានលទ្ធភាពខ្ពស់ក្នុងការអភិវឌ្ឍជាតិលើគ្រប់វិស័យ។

*សម្រាប់ក្របខ័ណ្ឌទំនាក់ទំនងការទូត និងកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ចិន* ក្នុងជំនួបទ្វេភាគីជាមួយ **ឯកឧត្តម លី ឈាង** នាយករដ្ឋមន្ត្រីចិន **សម្តេចធិបតី** បានគូសបញ្ជាក់អំពីជំហរនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចធិបតី** ក្នុងការបន្តអនុវត្តនយោបាយចិនមួយ យ៉ាងខ្ជាប់ខ្ជួន និងគាំទ្រការរៀបចំគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ លើកទី៣។ **សម្តេចធិបតី** ក៏បានស្នើសមភាគីចិនពិនិត្យពិចារណាគម្រោងពាក់ព័ន្ធនឹងសន្តិសុខថាមពល ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ការជំរុញ និងលើកទឹកចិត្តផ្នែកវិនិយោគ ការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការត្បូងពេជ្រ ក៏ដូចជាការស្តារ និងជំរុញវិស័យទេសចរណ៍។ **ឯកឧត្តម** នាយករដ្ឋមន្ត្រីចិន បានថ្លែងអំណរគុណចំពោះសំណើនេះ ហើយបញ្ជាក់ពីភាពរីករាយក្នុងការបន្តសហការ និងជំរុញអនុវត្តឱ្យចេញជាលទ្ធផល។ ថ្នាក់ដឹកនាំទាំងពីរ ក៏បានឯកភាពគ្នាបន្តគាំទ្រ និងជួយជ្រោមជ្រែងគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌតំបន់ និងសាកល។ បន្ទាប់មក នាយករដ្ឋមន្ត្រីទាំងពីរ ក៏បានបន្តអញ្ជើញជាអធិបតី ក្នុងពិធីចុះហត្ថលេខាលើឯកសារសហប្រតិបត្តិការចំនួន **១៥** ក្នុងនោះក៏មានឯកសារស្តីពីផែនការសកម្មភាព នៃការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី ឆ្នាំ២០២៤-២០២៨ និងកិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងសាងសង់ស្ពានទន្លេបាសាក់(ចាក់អង្រែក្រោម-ព្រែកប្រា) ជាដើម។

*ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចពហុភាគី និងវិស័យឯកជន* **សម្តេចធិបតី** បានទទួលជួបប្រធានក្រុមហ៊ុនចិនធំៗកម្រិតអន្តរជាតិ រួមមានក្រុមហ៊ុន SINOMACH Heavy Equipment Group ក្រុមហ៊ុន China Road and Bridge Corporation (CRBC) ក្រុមហ៊ុន China Huaneng Group និងក្រុមហ៊ុន Huawei Technology Co., Ltd។ ក្រៅពីនេះ **សម្តេចធិបតី** បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយ **សហគ្រាសឧស្សាហកម្ម និងពាណិជ្ជកម្មកម្ពុជា-ចិន**។ ក្នុងកិច្ចពិភាក្សា និងជំនួបសំណេះសំណាលនោះ **សម្តេចធិបតី** បានគូសបញ្ជាក់អំពីទិន្នផលគ្រប់ជ្រុងជ្រោយដែលកើតចេញពីកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រ និងប្រកបដោយទំនុកចិត្តខ្ពស់បំផុតរវាងកម្ពុជា និងចិន ព្រមទាំងសារៈសំខាន់ និងភាពអំណោយផលនៃច្បាប់ស្តីពីវិនិយោគដែលមានយន្តការលើកទឹក

ចិត្តដ៏ទាក់ទាញ និងជាក់លាក់ ក៏ដូចជាអំណោយផល នៃច្បាប់ស្តីពីភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។ ប្រធានក្រុមហ៊ុនចិនកម្រិតអន្តរជាតិ បានបង្ហាញការគាំទ្រចំពោះការដឹកនាំរបស់ **សម្តេចធិបតី** និងបានបញ្ជាក់អំពីការត្រៀមខ្លួនពង្រីកនូវគម្រោងវិនិយោគថ្មីៗបន្ថែមទៀត នៅកម្ពុជា។ **សម្តេចធិបតី** បានស្វាគមន៍ និងបញ្ជាក់ពីការត្រៀមគាំទ្រ និងសម្របសម្រួលជូនវិនិយោគិនចិន មកសិក្សាស្វែងយល់ពីសក្តានុពលវិនិយោគ នៅកម្ពុជា។

បន្ទាប់ពីបញ្ចប់ទស្សនកិច្ចផ្លូវការ **សម្តេចធិបតី** ក៏បានបន្តដឹកនាំគណៈប្រតិភូ អញ្ជើញចូលរួមក្នុង**ពិធីបើកពិព័រណ៍អាស៊ាន-ចិន និងកិច្ចប្រជុំកំពូលធុរកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់លើកទី៣** (RCEP) នៅទីក្រុងណាននីង ខេត្តក្វាងស៊ី។ នាឱកាសនោះ **សម្តេចធិបតី** បានអនុញ្ញាតឱ្យ **ឯកឧត្តម លាវ នីង** លេខាបក្សតំបន់ស្វយ័តជនជាតិជាំងក្វាងស៊ី ចូលជួបសម្តែងការគួរសម ដោយក្នុងជំនួបនោះ **ឯកឧត្តម លាវ នីង** បានអបអរសាទរជូន **សម្តេចធិបតី** ដែលត្រូវបានរដ្ឋសភាជ្រើសតាំងជានាយករដ្ឋមន្ត្រី និងបានគោរពរាយការណ៍ជូនអំពីសក្តានុពល ឧត្តមភាព និងភាពខ្លាំង នៃតំបន់ស្វយ័តជនជាតិជាំងក្វាងស៊ី ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ក្នុងវិស័យពាណិជ្ជកម្ម កសិកម្ម សុខាភិបាល បច្ចេកវិទ្យា ការអប់រំ កីឡា និងការបណ្តុះបណ្តាល ធនធានមនុស្ស។ **ភាគីចិន** និង **កម្ពុជា** ក៏បានឯកភាពគ្នាពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការដែលមានស្រាប់ ខិតខំបន្ថែមទៀតក្នុងការជំរុញអភិវឌ្ឍវិស័យទេសចរណ៍ ការបង្កើនជើងហោះហើរត្រង់ ព្រមទាំងពិនិត្យលទ្ធភាពពន្លឿនដំណើរការរៀបចំនីតិវិធីចុះអនុស្សរណៈ នៃកិច្ចសហប្រតិបត្តិការរួមគ្នា ស្តីពីការសាងសង់សួនឧស្សាហកម្មកម្ពុជា-ចិន ដែលផ្តោតការយកចិត្តទុកដាក់លើសេដ្ឋកិច្ចឌីជីថល និងកសិកម្មវៃឆ្លាត។ នៅទីក្រុងណានីងនោះដែរ **សម្តេចធិបតី** និង **លោកជំទាវ** បានអញ្ជើញចូលរួមពិធីជប់លៀងផ្លូវការ រៀបចំដោយ **ឯកឧត្តម** នាយករដ្ឋមន្ត្រីចិន និងបានឆ្លៀតសំណេះសំណាលជាមួយថ្នាក់ដឹកនាំប្រទេសសមាជិកអាស៊ានផ្សេងទៀតផងដែរ។

*នាពិធីបើកពិព័រណ៍អាស៊ាន-ចិន លើកទី២០ ក្រោមមូលបទ «រួមគ្នាកសាងសហគមន៍មួយ ប្រកបដោយភាពសុខដុម និងវាសនាតែមួយ»* **សម្តេចនាយករដ្ឋមន្ត្រី** បានអញ្ជើញថ្លែងសុន្ទរកថាដោយគូសបញ្ជាក់ថា **កិច្ចសហប្រតិបត្តិការអាស៊ាន-ចិន គឺជាតួអង្គដ៏សំខាន់ក្នុងការបង្ហាញឧទាហរណ៍ដល់ពិភពលោកអំពីផលប្រយោជន៍កើតចេញពីការពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគី ដោយមិនទោរទន់ទៅរកនិន្នាការគាំពារនិយម ឯកតោភាគីនិយម ឬគំនិតជាតិនិយមសេដ្ឋកិច្ច។** **សម្តេចធិបតី** ក៏បង្ហាញការប្តេជ្ញាបន្តប្រឹងប្រែងកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ តាមរយៈការកាត់បន្ថយចំណាយធុរកិច្ច និងបង្កើនប្រសិទ្ធភាព នៃវិស័យដឹកជញ្ជូន និងឡូជីស្ទិក ក្នុងគោលបំណងដើម្បីលើកកម្ពស់ផលិតភាព ឆ្លើយតបនឹងតម្រូវការរបស់វិនិយោគិនពីគ្រប់មជ្ឈដ្ឋាន។ ក្នុងឱកាសនោះ **សម្តេចធិបតី** ក៏បានអញ្ជើញកាត់ខ្សែបូសម្ពោធពន្លាជាតិ និងស្តង់ពិព័រណ៍កម្ពុជា រៀបចំដោយក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងសហគ្រាសធុនតូច និងមធ្យម ពីប្រទេសកម្ពុជា ជាច្រើនទៀត។

បន្ទាប់មក **សម្តេចធិបតី** បានអនុញ្ញាតឱ្យ **ឯកឧត្តម ឡាន ឆានលី** អភិបាល នៃតំបន់ស្វយ័តជនជាតិជាំងក្វាងស៊ី ចូលជួបសម្តែងការគួរសម ដោយនៅក្នុងជំនួបនោះ **សម្តេចធិបតី** បានស្នើ **ឯកឧត្តមអភិបាល** ជួយគាំទ្រ និងជំរុញការអនុវត្តកិច្ចសហប្រតិបត្តិការដែល **សម្តេចធិបតី** បានឯកភាពជាមួយ **ឯកឧត្តម** លេខា

បក្សតំបន់ស្វយ័តជនជាតិជាំងក្វាងស៊ី។ ជាការឆ្លើយតប **ឯកឧត្តម ឡាន ឆានលី** បានសន្យាជំរុញ និងគាំទ្រឱ្យកិច្ចសហប្រតិបត្តិការទាំងនោះចេញជាផ្លែផ្កា ជាពិសេសការបង្កើនជើងហោះហើរត្រង់រវាងកម្ពុជា និងក្វាងស៊ី។

*សម្រាប់កិច្ចប្រជុំកំពូលធុរកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់លើកទី៣ (RCEP)* **សម្តេចធិបតី** បានអញ្ជើញថ្លែងសុន្ទរកថាដោយចាត់ទុកក្របខ័ណ្ឌតំបន់ RCEP ថានៅតែជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីធំជាងគេបំផុតលើពិភពលោក ដែលមានលក្ខណៈទំនើប រស់រវើក គ្រប់ជ្រុងជ្រោយ និងមានគុណភាពខ្ពស់។ ភ្ជាប់នឹងទស្សនាទានគន្លឹះ**៥ចំណុច** សំខាន់ៗ **សម្តេចធិបតី** បានសង្កត់ធ្ងន់ពីសារៈសំខាន់របស់ RCEP ក្នុងការពង្រឹងទំនុកចិត្តលើប្រព័ន្ធពាណិជ្ជកម្មពហុភាគី ការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិ និងការជំរុញសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក ដោយឈរលើគោលការណ៍ឈ្នះ-ឈ្នះ និងការផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។

លទ្ធផលជាក់ស្តែងដូចបានសង្ខេបជូនខាងលើនេះ គឺជាសមិទ្ធផលដ៏ធំធេងដែលរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** សម្រេចបានជូនជាតិមាតុភូមិ និងប្រជាពលរដ្ឋខ្មែរ ក្នុងដំណើរទស្សនកិច្ចលើកដំបូងទៅកាន់សាធារណរដ្ឋប្រជាមានិតចិន បន្ទាប់ពីជោគជ័យដ៏ធំធេងដែលកម្ពុជាទើបទទួលបាននៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅទីក្រុងហ្សាការតា កាលពីពេលថ្មីៗនេះ។

ដោយឡែក ក្នុងអំឡុងពេលបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិននោះដែរ **សម្តេចមហាបវរធិបតី** និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** បានទទួលព្រះបរមរាជានុញ្ញាតចូលបង្គំគាល់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះរាជដំណាក់ក្រុងប៉េកាំង ក្នុងឱកាសព្រះអង្គទាំងទ្វេយាងទទួលការថ្វាយនូវការពិនិត្យព្រះរាជសុខភាព ដោយក្រុមវេជ្ជបណ្ឌិតចំណានៗ នៃសាធារណរដ្ឋប្រជាមានិតចិន។ ក្នុងឱកាសរួមដំណើរជាមួយ **សម្តេចធិបតី** បំពេញទស្សនិច្ចផ្លូវការនោះដែរ **លោកជំទាវបណ្ឌិត** ក៏បានអញ្ជើញទស្សនាមហាកំផែង និងធ្វើទស្សនកិច្ចនៅមហាវិមានប្រជាជនផងដែរ។

ថ្ងៃអាទិត្យ ៣កើត ខែកត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣